## វគ្គសិក្សាស្ដីពី

# ផលិតកម្មដំណាំត្រាវ

### សំរាប់ផ្សព្វផ្សាយកសិកម្ម


**បង្រៀនដោយ : លោក ទេព ចាន់ដារ៉ា**

011 955 250








2007-2008

Kg Speu 20-22 មិថុនា 2007

# វគ្គសិក្សាស្ដីពី

ម.ព.ឯ.ក AIDOC
Code: 107-007
Date:
Donated by:

# ផលិតកម្មដំណាំត្រាវ

## សំរាប់ផ្សព្វផ្សាយកសិកម្ម

បង្រៀនដោយ : លោក ទេព ចាន់ដារ៉ា




011 955 250




2007-2008

## មាតិកាអត្ថបទ

**១.ប្រវត្តិនិងស្ថានភាពដាំដុះសារៈប្រយោជន៍នៃដំណាំត្រាវ**..........១

**២.លក្ខណៈរូបសាស្ត្រដំណាំត្រាវ**..........១

ក.ប្រពន្ធ័រឫស..........១

ខ.ដើម..........២

គ .ធាង..........២

ឃ .ផ្កា..........២

ង.ស្លឹក..........២

ច.មើម..........២

**៣.លក្ខណៈបរិស្ថាន**..........៤

ក .សីតុណ្ហភាព..........៤

ខ.ពន្លឺ..........៤

គ.របបទឹកភ្លៀង..........៤

ឃ.ដី..........៤

**៤.បច្ចេកទេសដាំដុះ**..........៥

ក.ការរៀបចំដី..........៥

ខ.ការដាំដុះ..........៥

**៥.ពូជ.** COLOCASIA ANTIQUORUM EDDOE..........៨

**៦.ពូជ.** XANTHOSOMA SAGITTIFOLIUM..........៨

៧.ជំងឺនិងសត្វល្អិត..........៩

ជំងឺRoot rot..........៩

៨.ការប្រមូលផល..........១០

# ដំណាំត្រាវ

ត្រាវស្ថិតនៅក្នុងគ្រួសារ Family Name : Araceae

ឈ្មោះភាសាអង់គ្លេស English Name: Taro

ឈ្មោះវិទ្យាសាស្ត្រScientific Name: Colocasia eseulenta

**លក្ខណពូជ**

- Colocasia esaulenta ត្រាវស្លាគេនិយមបរិភោគ
- Colocasia antiquorum ត្រាវទឹកជាចំណើសត្វវារមាស់
- Xanthosoma Sagittifolium ( កូនដើមតូច សឹកឆែក

## ១~ ប្រវត្តិស្ថានភាពដាំដុះនិងសារៈប្រយោជន៍របស់ដំណាំត្រាវ

ដំណាំត្រាវបានលូតលាស់នៅអាស៊ីអាគេយ៏ ហើយត្រូវបានដាំមុនគេបង្អស់នៅប្រទេសចិន បន្ទាប់មកនៅជប៉ុន និង រាលដាលទៅដល់តំបន់ខាងកើតនៃសនុទ្រមេឌីទែរ៉ាណេ ហើយឆ្លងកាត់អាហ្វ្រិក ទៅ Guinea ។ ប្រភេទត្រាវផ្សេងៗ ទៀត Dasheen មានដើមកំណើតនៅ Columbian និង ត្រូវបានដាំដុះមុនគេបង្អស់ឥណ្ឌា និង ជាដំណាំដែលប្រជាជនឥណ្ឌានៅភាគខាងត្បូងនិមយដាំបំផុត ។ នៅអាហ្វ្រិកខាងត្បូងប្រជាជននិយមដាំយកមើមបរិភោគ ដូចជាចៀន ស្ងោរ និង ចិតស្តើងៗហាលអោយស្ងួត បុកធ្វើម្សៅ និង កែច្នៃធ្វើនំផ្សេងៗ ។ មិនថាតែប្រជាជនអាហ្វ្រិកទេដំណាំត្រាវជាអាហារសំខាន់បំផុតសំរាប់មនុស្សជាតិ គេអាចយកដើមត្រាវទៅធ្វើជាបង្អែម ឬ ស្ងោរហូបធម្មតាក៏បានគេអាចយកមើមរបស់វា ឬ ធាង ធ្វើជាបន្លែស្លរបរិភោគ ។ ដំណាំត្រាវសំបូរដោយសារធាតុដែលគេសង្កេតឃើញសារធាតុមួយចំនួននៅក្នុងមើម របស់ពួក Dasheen ជាតិទឹក ៦៣-៨៥ ភាគរយ. ប្រូតេអ៊ីន ១.៤-៣.០ ភាគរយ. ខ្លាញ់ ០.២-០.៤ភាគរយ. កាបូនអ៊ីដ្រាត ១៣-២៩ភាគរយ. ជាតិសរសៃ ០.៦-១.២ភាគរយ. ជាតិផេះ ០.៦-១.៣ភាគរយ និង វីតាមីន B និង C ចំណែកឯស្លឹកមានផ្ទុំដោយជាតិទឹក ៨៧.២ ភាគរយ. ប្រូតេអ៊ីន ៣.០ភាគរយ ខ្លាញ់ ០.៨ភាគរយ. កាបូនអ៊ីដ្រាត ៦.០ភាគរយ. ជាតិសរសៃ ១.៤ភាគរយ. ផេះ ១.៦ភាគរយ ហើយនោស្លឹកត្រាវជាប្រភពនៃវីតេមីន C ។ចំណែកនៅប្រទេសកម្ពុជាវិញដំណាំត្រាវជាដំណាំមួយដែលកសិករនិយមដាំសុះសាយនៅក្នុងប្រទេស ពិសេសនៅតាមតំបន់តាមមាត់ទន្លេមេគង្គ ទន្លេបាសាក់ និង ជុំវិញបឹងទន្លេសាប ។ ខេត្តផ្សេងៗទៀត ក៏មានដាំបន្ទាប់បន្សំក្នុងលក្ខណៈគ្រួសារ ។

## ២~ លក្ខណៈរូបសាស្ត្ររបស់ប្រភេទត្រាវ Colocasia esculenta ( Dusheen )

**ក.ប្រពន្ធ័ឬស:** ឫសជាផ្នែកមួយនៃសរីរាង្គរុក្ខជាតិ ដែលវាមានតួនាទីសំខាន់បំផុតសំរាប់ស្រូបយកទឹក និង សារធាតុចិញ្ចឹមពីក្នុងដី និង ទ្រទ្រង់ដើមដង ។

ប្រព័ន្ធឫសរបស់ដំណាំត្រាវ ជាប្រភេទឫសស្មៃដែលវាដុះចេញពីថ្នាំងរបស់ដើមមើមរបស់វាគ្មានឫសកែវទេ ។ ឫសរបស់ត្រាវវាចាក់ចុះទៅក្នុងដីបានរាក់ ដូចនេះវាទាមទារធ្វើដីអោយបានល្អ ដើម្បីអោយវាចាក់បានជ្រៅដើម្បីស្រូបយកជីវជាតិ ។ នៅលើឫសស្មៃនេះមានឫសតូចឆ្មា១ ដូចជារោមដុះពីលើ គេហៅថាឫសជញ្ជក់ដែលវាមានតួនាទីយ៉ាងសំខានក្នុងការស្រូបយកជីវជាតិពីក្នុងដី ។ ឫសចាស់មានពណ៌ផ្កាឈូក. ដ្យាម៉ែត្រឫស ៣-៧មម. ប្រវែងឫសសំខាន់១ (ធំ) ៣៥-៤៥សម ឫសបែកខាង១មានប្រវែងរហូតដល់ ២ម ។ ឫសត្រាវនៅតូចខ្ចី មានពណសស្តើង ។

**ខ.ដើម** ត្រាវជាប្រភេទដើមមើមដែលដុះនៅកុងដី ។ វាមានរាងប៉ោងមូល ហើយស្ងួចចុង ដើមមានកំពស់ ៦០-៩០ ស.ម មើមសំបូរដោយអាមីដុង ហើយសាច់របស់វាមានពណ៌ស កូលាប ឬក្រហមព្រឿង ។ ផែកខាងក្រៅមានពណ៌រាងក្រមៅ មានលក្ខខណ្ឌ័ល វាលូត លាស់យ៉ាងរហ័ស បង្កើតជាសឹកដូចដើមមេវាដែរ ។ នៅពីលើថ្នាំងរបស់ត្រាវ គេឃើញមានស្រកាសឹក (រៀចាលេ-លពាថ) ដុះតាមថ្នាំងរបស់វា ។

**គ.ធាងត្រាវ** ធាងត្រាវស្ថិតនៅចនោះដើម (មើម) និងសឹក ។ វាមានពណ៌បៃតង មានប្រវែង ៣០-៦០ ស.ម ។ ផែកខាងកុងរបស់ធាងមានសភាពស្ពោត ។

**ឃ.ផ្កា** ផ្កាត្រាវមានលក្ខណដំណើរលំអងកាត់ និងលំអងឯង

**ង.សឹក** ដំណាំត្រាវវាមានសឹក រាងជាខែល ហើយមនពណ៌បៃតងព្រលែត ឬបៃតងក្រមៅ រូបរាងសឹកមានលក្ខណ ខុសគាដែរទៅតាមពូជ ។ ហើយទំហំសឹកក៏មានការខុសគាទៅតាមពូជដែរ ។

**ច.មើម**មើមត្រាវមានរាងដូចបំពងស៊ីឡាំងមានប្រពន្ធ័សរសដុះជុំវិញនិងមានស្នាមពក១ដែលជាកត្តាអោយវាដុះពន្លកបាន ។